

### ៣. កណ្តូបអង់តែនវែង (Meadow grass hopper)

- កណ្តូបអង់តែនវែង ជាសត្វល្អិតមានប្រយោជន៏
- វាអាចស៊ីពងរបស់ស្រឹងស្រូវ និងពងរបស់ដង្កូវស៊ីរូងដើមជាចំណី ហើយវាក៏អាចចាប់កូន របស់ពពួកមមាចត្នោត និងមមាចបៃតងផងដែរ ។



### ៤. ស្រឹងគោកទ្រូងខ្មៅ (Plant bug)

- ស្រែដែលមានពពួកមមាចត្នោត គេក៏សង្កេតឃើញ មានវត្តមានពពួកសត្វល្អិតនេះច្រើនដែរ
- វាស្វែងរកពង និងកូនរបស់មមាចជាចំណី
- សត្វស្រឹងគោកទ្រូងខ្មៅ មួយអាចស៊ីពងមមាចពី ៧-១០ពង ឬមមាចពី ១-៥ ក្បាលក្នុង១ថ្ងៃ ។



### ៥. កន្ធុំរុយ (Damselflies)

- ពួកវាច្រើនហើរនៅខាងលើ ចុងស្រូវ ដើម្បីស្វែងរក ចាប់សត្វល្អិតចង្រៃជាចំណី ( ពពួកមមាច, មេអំបៅ)
- កូនរបស់កន្ធុំរុយរស់នៅក្នុងទឹក ហើយ អាចឡើងលើដើមស្រូវ ដើម្បីចាប់ពពួក កូនមមាចស៊ីជាចំណី ។



### ៧. ពួកឪម៉ាល់ -ប៉ារ៉ាស៊ីតលើពងដង្កូវស៊ីរូងដើម (Wasp)

- នៅតាមវាលស្រែនៃប្រទេសកម្ពុជា គេសង្កេតឃើញ មានពួកឪម៉ាល់ជាច្រើនប្រភេទ ដែលអាចប៉ារ៉ាស៊ីតទៅលើពង និងដង្កូវរបស់សត្វចង្រៃ ។




ផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
National Road Nº 3, Prateah Lang Commune, Dangkor District,
Phnom Penh, Kingdom of Cambodia
ទូរសព្ទ័លេខ (៨៥៥-២៣) ២១៩ ៦៩៣/៤ ទូរសារ (៨៥៥-២៣) ២១៩ ៨០០
Tel: (855 23) 219 693/4, Fax: (855 23) 219 800

ប្រអប់សំបុត្រ ០១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
P.O. Box 01, Phnom Penh, Kingdom of Cambodia,
Email: cardi@cardi.org.kh, Web site: www.cardi.org.kh

**រៀបចំដោយ** : កម្មវិធីការពារដំនាំ
Prepared by : Plant Protection Program

**ឧបត្ថម្ភដោយ** :
Funded by :

Food and Agriculture Organization
of the United Nations




# កត្តាចង្រៃលើដំណាំស្រូវ

# *Rice Pest*



វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Cambodian Agricultural Research and Development Institute

## ១. សត្វល្អិតចង្រៃសំខាន់ៗលើដំណាំស្រូវ



### ១. មមាចត្នោត (Brown planthopper)

- ជញ្ជក់រុក្ខរសពីដើមស្រូវ ធ្វើអោយដើមស្រូវ មានភាពឆេះខ្លោច (Hopper burn)
- ភ្នាក់ងារចំលងជំងឺវីរុស : ជំងឺតឿរួញស្លឹក និង ជំងឺ តឿស្មៅ ។



### ២. ដង្កូវមូរស្លឹក (Leaf folder)

- ដង្កូវមូរស្លឹក គឺជាសត្វល្អិតចង្រៃដែលជួបប្រទះស្ទើរ តែគ្រប់វាលស្រែ និងគ្រប់ដំណាក់កាលលូតលាស់
- ការបំផ្លាញលើស្លឹកទង់ជ័យ ធ្វើអោយបាត់បង់ទិន្នផលស្រូវច្រើន ។



### ៣. មូសផ្លុង (Gall midge)

- ជួបប្រទះច្រើននៅខេត្តស្វាយរៀង និងកំពត
- បំផ្លាញស្រូវនៅដំណាក់កាលបែកគុម្ព
- ដើមស្រូវដែលរងនូវការបំផ្លាញ មានសភាពដូចស្លឹកខ្ទឹម ។



### ៤. ស្រឹងជញ្ជក់ទឹកដោះ (Rice bug)

- កូន និងមេចំណាស់ជញ្ជក់គ្រាប់ស្រូវនៅដំណាក់កាលដាក់ទឹកដោះ ដោយប្រអប់ មាត់ជញ្ជក់របស់វា
- វាបញ្ចេញក្លិនឆ្អេះស្អុយនៅពេលរំខានវា ។



### ៥. កណ្តូបស្រូវ (Grass hopper)

- កូន និងមេចំណាស់ស៊ីបំផ្លាញស្លឹកស្រូវ ដោយកាត់ គែមស្លឹកស្រូវ ។

## ២. ជំងឺសំខាន់ៗលើដំណាំស្រូវ



### ១. ជំងឺអុចត្នោត (Brown spot)

- ជំងឺនេះច្រើនកើតមាននៅលើស្លឹកស្រូវ
- អុចត្នោតលើស្លឹកមានរាងពងក្រពើ ឬមូលទ្រវែង ដែលមានទំហំប្រហាក់ប្រហែលនឹងគ្រាប់ល្ង
- នៅចំកណ្តាលនៃជំងឺអុចត្នោតនេះ មានពណ៌ប្រផេះ ឬពណ៌ស ។



### ២. ជំងឺអុចត្នោតវែង (Narrow brown spot)

- ជំងឺនេះច្រើនកើតមាននៅលើស្លឹក និងស្រទបស្លឹក
- ស្នាមដំបៅនៃជំងឺនេះមានរាងទ្រវែងពណ៌ត្នោត ។



### ៣. ជំងឺដុំធ្យូងបៃតង (False smut)

- រោគសញ្ញារបស់ជំងឺនេះអាចមើលដឹងនៅពេលគ្រាប់ស្រូវចាប់ផ្តើមទុំ
- គ្រាប់ស្រូវក្លាយជាដុំស្ព័រ ដែលផ្នែកខាងក្រៅមានពណ៌បៃតង និងពណ៌លឿងទុំនៅផ្នែកខាងក្នុង ។

## ៣. សត្វចង្រៃផ្សេងៗទៀត លើដំណាំស្រូវ



### ១. ខ្យងពណ៌មាសស៊ីស្រូវ (Golden apple snail)

- ខ្យងស៊ីស្រូវត្រូវបានគេរកឃើញមាននៅប្រទេស កម្ពុជានៅឆ្នាំ១៩៩៥
- ជាប្រភេទកត្តាចង្រៃថ្មីលើដំណាំស្រូវ
- វាមានលក្ខណៈខុសពីខ្យងក្នុងស្រុក :
  - សំបកខ្យងពណ៌លឿង, លឿងក្រម៉ៅ
  - សាច់ខ្យងពណ៌លឿង
  - ពងខ្យងពណ៌ផ្កាឈូក ។



### ២. កណ្តុរស្រែ (Rice-field rat)

- កណ្តុរជាសត្វចង្រៃសំខាន់មួយ លើដំណាំកសិកម្មក្នុងផ្នែកជាច្រើននៃប្រទេសកម្ពុជា
- កណ្តុរស្រែសំខាន់នៅកម្ពុជាមានប្រភេទ *Rattus argentiventer, Rattus losea, Bandicota indica, Rattus rattus, Mus coroli* និង *Mus cervicolor*
- កណ្តុរស្រែអាចបំផ្លាញស្រូវក្រោយពេលប្រមូលផល ជាមធ្យម ៥ ទៅ ១៨% ហើយអាចបំផ្លាញរហូតដល់ ១០០% នៅក្នុងឆ្នាំដែលមានការបំផ្លាញខ្លាំង ។

## ៤. សត្វល្អិតមានប្រយោជន៍



### ១. អណ្តើកមាស (*Micraspis crocea*)

- ជួបប្រទះវាច្រើននៅតាមវាលស្រែ
- កូន និងមេចំណាស់អាចចាប់ពពួកមមាចស៊ី
- វាធ្វើសកម្មភាពចាប់ចំណីនៅពេលថ្ងៃ ។



### ២. ខ្ទួតដី (*Ophionea nigrofasciata*)

- ខ្លួនវាមានពណ៌ក្រហមត្នោត
- ខ្ទួតដីស្វែងរកចាប់ចំណីនៅផ្នែកខាងលើនៃដើមស្រូវ ជាពិសេសចាប់ដង្កូវមូរស្លឹកជាចំណី ។



### ៦. ពីងពាងថ្គាមវែង (Tetragnathidea)

- នៅក្នុងស្រែនៃប្រទេសកម្ពុជា គេជួបប្រទះមានពីងពាង ជាច្រើនប្រភេទដែលអាចចាប់សត្វល្អិតចង្រៃជាចំណីបាន ។